**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

70th Anniversary of Diplomatic Relations between CAMBODIA - JAPAN

*ថ្ងៃពុធ ៥រោច ខែបុស្ស ឆ្នាំខាល ពស២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ ២០២៣*

# សេចក្តីប្រកាសព័ត៌មានរួម

## ស្តីពី ការចុះហត្ថលេខាលើកំណត់ហេតុពិភាក្សានៃ "គម្រោងអភិវឌ្ឍន៍ផែនទីបង្ហាញផ្លូវអន្តរកាលថាមពលឆ្ពោះទៅរកសង្គមអព្យាក្រឹត្យកាបូន"

នារសៀលថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងរ៉ែនិងថាមពល កំណត់ហេតុនៃកិច្ចពិភាក្សាស្តីពី **"គម្រោងអភិវឌ្ឍន៍ផែនទីបង្ហាញផ្លូវអន្តរកាលថាមពលស្អាតឆ្ពោះទៅរកសង្គមអព្យាក្រឹតកាបូន"** ក្រោមគម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេសរវាងក្រសួងរ៉ែនិងថាមពល និងរដ្ឋាភិបាលជប៉ុន ត្រូវបានចុះហត្ថលេខាដោយ **ឯកឧត្តមបណ្ឌិត ទី នរិន្ទ** រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល និង**លោកស្រី Kamei Haruko** ប្រធានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ប្រចាំកម្ពុជា។

គម្រោងនេះមានគោលបំណងអភិវឌ្ឍន៍ផែនទីបង្ហាញផ្លូវឆ្ពោះទៅរកសង្គមដែលមានអព្យាក្រឹតកាបូនសម្រាប់ប្រទេសកម្ពុជាជាមួយនឹងការរក្សាឱ្យបាននូវតុល្យភាពនៃសន្តិសុខថាមពល កំណើនសេដ្ឋកិច្ច និងកិច្ចការពារបរិស្ថាន។ គម្រោងនេះនឹងត្រូវចាប់ផ្តើមអនុវត្តនៅខែមីនា ឆ្នាំ២០២៣ ខាងមុខនេះ។

ក្នុងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រសួងរ៉ែនិងថាមពល និងភាគីពាក់ព័ន្ធ ក្រុមជំនាញការរបស់ JICA នឹងពិនិត្យលើគោលនយោបាយ និងសេណារីយ៉ូពាក់ព័ន្ធទាំងអស់ វិភាគលើគុណសម្បត្តិនិងគុណវិបត្តិនៃសេណារីយ៉ូនីមួយៗព្រមទាំងកំណត់អំពីបច្ចេកវិទ្យានិងវិធានការណ៍ជាអាទិភាពទាំងឡាយដែលត្រូវសម្រេចដាក់ឱ្យប្រើប្រាស់ ជាមួយនឹងការរៀបចំសកម្មភាពគោលនយោបាយ ក្របខណ្ឌទទួលខុសត្រូវរបស់ស្ថាប័ន និងគម្រោងនិងយុទ្ធសាស្ត្រវិនិយោគ។ យោងតាមលទ្ធផលនៃការវិភាគនិងអនុសាសន៍ទាំងនេះ សេណារីយ៉ូចុងក្រោយបំផុតដែលសមស្របជាងគេនៃផែនទីបង្ហាញផ្លូវនេះ នឹងកំណត់អំពីផែនការសកម្មភាពនានា ដែលក្រសួងរ៉ែនិងថាមពលត្រូវអនុវត្តឆ្ពោះទៅរកសង្គមអព្យាក្រឹតកាបូន។

យើងជឿជាក់ថា ជាមួយនឹងការខិតខំប្រឹងប្រែងរួមគ្នារវាងភាគីទាំងពីរ គម្រោងរៀបចំផែនទីបង្ហាញផ្លូវនេះ នឹងចូលរួមចំណែកដល់ការសម្រេចឱ្យបាននូវសង្គមអព្យាក្រឹតកាបូន សម្រាប់ប្រទេសកម្ពុជាត្រឹមឆ្នាំ ២០៥០។ ៕

*លោកបណ្ឌិត ឈួន សម្បត្តិរតនៈ៖ ប្រធាននាយកដ្ឋានបច្ចេកទេស និងគោលនយោបាយអាជីវកម្មថាមពល នៃក្រសួងរ៉ែនិងថាមពល,*
*អ៊ីម៉ែល : csratanak@yahoo.com ឬ ទូរសព្ទទំនាក់ទំនង: 096 789 1616*
*លោក គង់ វិសិដ្ឋ៖ មន្ត្រីគម្រោងទទួលបន្ទុកផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍន៍ឧស្សាហកម្ម នៃចៃកាកម្ពុជា*
*អ៊ីម៉ែល : kong-viseth@jica.go.jp ឬ ទូរសព្ទទំនាក់ទំនង: 017 555 897*

********************